**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការទាំងអស់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានតាមដានដោយការយកចិត្តទុកដាក់ខ្ពស់បំផុត ចំពោះព្រឹត្តិការណ៍ជាតិពាក់ព័ន្ធនឹងបញ្ហាផែនទីព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាពិសេសព្រឹត្តិការណ៍ចុងក្រោយទាក់ទងនឹងការផ្ទៀងផ្ទាត់ផែនទី ដែលផ្តល់ដោយអង្គការសហប្រជាជាតិ និងដោយសាធារណរដ្ឋបារាំងតាមសំណើសុំខ្ចីរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាមួយនឹងផែនទីព្រំដែនផ្លូវការ និងស្របច្បាប់ដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រើប្រាស់ក្នុងការកំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។ ការផ្ទៀងផ្ទាត់ផែនទីទាំងពីរលើក នៅវិមានសន្តិភាពនាថ្ងៃទី២០ ខែសីហា និងថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ បានប្រព្រឹត្តទៅក្នុងលក្ខណៈបើកចំហរប្រកបដោយតម្លាភាពដោយមានការចូលរួមត្រួតពិនិត្យ និងសង្កេតការណ៍យ៉ាងទូលំទូលាយ ពីសំណាក់គ្រប់តួអង្គពាក់ព័ន្ធ ហើយលទ្ធផលនៃការផ្ទៀងផ្ទាត់បានបង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់ដោយគ្មានការសង្ស័យអំពីភាពត្រឹមត្រូវដូចគ្នាបេះបិទ រវាងខ្សែបន្ទាត់ព្រំដែននៃផែនទីទាំង១៨ផ្ទាំង ដែលអង្គការសហប្រជាជាតិបានឱ្យខ្ចី និងផែនទីច្បាប់ចម្លងទាំង២៦ផ្ទាំង ដែលសាធារណរដ្ឋបារាំងបានប្រគល់ឱ្យជាមួយនឹងផែនទីព្រំដែនខ្នាត ១/១០០ ០០០ ដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រើប្រាស់ក្នុងការកំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។

ទន្ទឹមនឹងនេះ យើងខ្ញុំទាំងអស់គ្នាក៏បានស្តាប់យ៉ាងយកចិត្តទុកដាក់បំផុតនូវសេចក្តីថ្លែងការណ៍ប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅជាប្រវត្តិសាស្ត្ររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីផ្តល់ការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជាស្តីពីផែនទី ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីសច្ចភាព និងភាពត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម ដោយធានាការពារឱ្យបាននូវបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងមិនឱ្យមានការបាត់បង់ជាដាច់ខាត សូម្បីតែមួយម៉ែតក្រឡាក៏ដោយ។ ជាមួយគ្នានេះដែរ ក៏បានបង្ហាញឱ្យឃើញច្បាស់ពីល្បិចកលនយោបាយដ៏ពិសពុលរបស់មជ្ឈដ្ឋានអគតិមួយចំនួន ដែលនៅតែបន្តបិទភ្នែក បិទត្រចៀកនិងធ្វើជាមិនយល់អំពីកិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធានាការពារបូរណភាពទឹកដីមិនឱ្យមានការបាត់បង់ និងបានបន្តលើក

យកប្រធានបទនេះមកធ្វើការឃោសនា ញុះញង់បំផុសបំផុល បំភ្លៃ បំផ្លើសនិងបំប៉ោងការពិត និងសភាពការណ៍ទាក់ទងនឹងបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម ក្នុងការបង្កើតឱ្យមានការយល់ដឹងដោយភាន់ច្រលំ និងមិនត្រឹមត្រូវលើបញ្ហាព្រំដែនក្នុងគោលបំណងបោកបញ្ឆោតទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូនប្រជាពលរដ្ឋខ្មែរ ចំពោះជាតិមាតុភូមិជាទីស្នេហារបស់ខ្លួន ដើម្បីគេអាចប្រើប្រាស់ជាឧបករណ៍ក្នុងគោលដៅ ធ្វើជាអាជីវកម្មនយោបាយរបស់គេ ដោយមិនខ្វល់ខ្វាយ និងគ្មានការទទួលខុសត្រូវចំពោះជោគវាសនា និងផលប្រយោជន៍របស់ប្រទេសជាតិឡើយ។

ជាថ្មីម្តងទៀត យើងខ្ញុំជាថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់ សូមប្រកាសគាំទ្រយ៉ាងឱឡារិកបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលតែងតែបានបូជាកម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ភ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុងឧត្តមក្នុងបុព្វហេតុការពារអធិតេយ្យ និងបូរណភាពទឹកដីរបស់ជាតិមាតុភូមិ និងសូមប្រកាសគាំទ្រទាំងស្រុងចំពោះរាជរដ្ឋាភិបាលក្នុងកិច្ចខំប្រឹងប្រែងប្រកបដោយការទទួលខុសត្រូវខ្ពស់ បន្តចរចារដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម ដោយផ្អែកលើសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងផែនទីព្រំដែនអមសន្ធិសញ្ញានេះដែលជាផែនទីផ្លូវការតែមួយគត់ដែលមានតម្លៃគតិយុត្តស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមច្បាប់អន្តរជាតិសំដៅកសាងខ្សែបន្ទាត់ព្រំដែនកម្ពុជាមួយដែលមានភាពច្បាស់លាស់ត្រឹមត្រូវ ប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះទង្វើរបស់ជនអគតិមួយចំនួនដែលតែងតែបានធ្វើការប្រឌិត និងចោទប្រកាន់មូលបង្កាច់ទាំងងងឹតងងល់នាពេលកន្លងមក ដើម្បីបម្រើនយោបាយប្រជាភិថុតរបស់ក្រុមខ្លួន មកលើកិច្ចខិតខំប្រឹងប្រែងយ៉ាងស្មោះសរ និងដើម្បីឧត្តមប្រយោជន៍ជាតិរបស់រាជរដ្ឋាភិបាលក្នុងការងារព្រំដែននេះ និងសូមអំពាវនាវម្តងហើយម្តងទៀតដល់អាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការតាមច្បាប់ឱ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋ ក្នុងគោលបំណងថែរក្សាសន្តិភាព ស្ថិរភាពសង្គម និង សណ្តាប់ធ្នាប់សាធារណៈ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

**អ៊ិត សំហេង**